**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តភ្នំពេញ**

PHNOM PENH AUTONOMOUS PORT

ថ្ងៃពុធ ៤ កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព. ស. ២៥៦៧

លេខ ៦១០/២៣ ....ក. ស. ភ.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣

# សេចក្ដីប្រកាសព័ត៌មាន

**កំពង់ផែស្វយ័តភ្នំពេញ** (**ក. ស. ភ.**) មានកិត្តិយសសូមជម្រាបជូនដល់វិនិយោគិន និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ កន្លងមក ក. ស. ភ. បានរៀបចំនូវ **ពិធីបើកឱ្យប្រើប្រាស់សាកល្បងនូវ ចំណតផែរណបពហុបំណង UM២** ស្ថិតនៅភូមិដូនម៉ៅលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ **និងចំណតផែរណបពហុបំណង LM២៦** ស្ថិតនៅភូមិកោះរកា ឃុំកោះរកា ស្រុកពាមជរ ខេត្តព្រៃវែង។

ចំណតផែរណបពហុបំណងទាំងពីរនេះ បង្កើតឡើងក្នុងគោលបំណងចម្បង គឺដើម្បីជំរុញ និងលើកកម្ពស់ការប្រមូលផ្ដុំ និងនាំចេញនូវទំនិញជាកសិផល និងទំនិញឧស្សាហកម្ម ព្រមទាំងទំនិញគ្រប់ប្រភេទមកពីតំបន់ជុំវិញ សម្រាប់បម្រើឱ្យការនាំចេញ-នាំចូល ទាំងក្នុង និងក្រៅប្រទេសឱ្យកាន់តែមានភាពងាយស្រួល និងឆាប់រហ័ស។ តាមរយៈការដាក់ឱ្យប្រើប្រាស់សាកល្បងនេះ ក៏នឹងជួយជំរុញឱ្យមានការដឹកជញ្ជូនទំនិញតាមផ្លូវទឹក ជំរុញកំណើនទំនិញឆ្លងកាត់ ក. ស. ភ. ពង្រីកវិសាលភាពអាជីវកម្ម/ប្រតិបត្តិការផែ និងកៀរគរប្រភពចំណូលបន្ថែមសម្រាប់ ក. ស. ភ. និងជួយលើកកម្ពស់ដល់សេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ សូមវិនិយោគិន និងសាធារណជនទាំងអស់ទទួលជ្រាបជាព័ត៌មាន។

**កំពង់ផែស្វយ័តភ្នំពេញ**